មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ និងមុនការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត លោកនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវជាច្រើនលើកច្រើនសារស្នើទៅគណបក្សនយោបាយដាក់បេក្ខភាពស្ត្រីឈរឈ្មោះបោះឆ្នោតនៅលេខរៀងខាងលើឱ្យបានជាប់ឆ្នោត។ ជាមួយគ្នានេះដែរ ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការងារសកម្ម អំពីស្ត្រី មានឈ្មោះថា "ក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នា" ចំនួន១២អង្គការ មានដូចជា ខុមហ្វ្រែល (COMFREL) និកហ្វិច(NICFEC) អង្គការចំរើនស្ត្រី(WfP) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) អង្គការសីលការ (SILAKA) និងសមាគមនារីកម្ពុជាដើម្បី សន្តិភាព និងអភិវឌ្ឍន៍ (CWPD) មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) អង្គការអមរា (AMARA) អង្គការបន្ទាយស្រី(Bantey Srey) និងអង្គការPYD ព្រមទាំងដៃគូអភិវឌ្ឍន៍(ម្ចាស់ជំនួយ)មួយចំនួនទៀតបានជំរុញ បង្កើនយុទ្ធនាការ និងបញ្ចុះបញ្ចូលគណបក្សនយោបាយ និង គ.ជ.បក្នុងការរៀបចំបញ្ជីបេក្ខជនឈរឈ្មោះឆ្លាស់គ្នារវាងបុរស និងស្ត្រី ឬនៅលេខរៀងខាងលើចំនួន៣0%ធ្វើយ៉ាងណាផ្តល់ឱកាសឱ្យស្ត្រីមានលទ្ធភាពជាប់ឆ្នោត ព្រមទាំងបានបណ្តុះបណ្តាលស្ត្រីទាំងនោះឱ្យមានសមត្ថភាព និងបង្កើនភាពអង់អាចក្លាហានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឃុំ សង្កាត់។ ជាក់ស្តែងកម្មវិធីខុមហ្វ្រែល ស្តីពី *"ស្ត្រីអាចធ្វើបាន និងការផ្តល់អំណាចឱ្យស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងនយោបាយ"* បានធ្វើការបណ្តុះបណ្តាលចំនួន៤១វគ្គ ដែលមានស្ត្រីសិក្ខាកាមចំនួន ១១០៧នាក់ និងហ្វឹកហាត់ស្ត្រីទាំងនោះតាមរយៈការធ្វើសកម្មភាពផ្សេងៗនៅថ្នាក់មូលដ្ឋាននៅក្នុងខេត្តគោលដៅចំនួន៥ គឺ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ។

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់គ.ជ.ប កាលពី ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះមានការកើនឡើងពី ១៦% (១២000នាក់)ក្នុងអាណត្តិទី១ឆ្នាំ២00២(ក្នុងចំណោម៨គណបក្សនយោបាយ)ទៅ ២១,៣៦% (២១៨៤0នាក់)ក្នុងអាណត្តិទី២ឆ្នាំ២00៧(ក្នុងចំណោម១២គណបក្សនយោបាយ)ទៅ ២៥,៦៤% (២៨៤៨១នាក់)ក្នុងអាណត្តិទី៣ឆ្នាំ២០១២ (ក្នុងចំណោម១0គណបក្សនយោបាយ)។ តួលេខនេះមានការកើនឡើងចំនួន **៤,២៨%** ពី ២១,៣៦% (អាណត្តិទី២ ឆ្នាំ២00៧) ទៅ ២៥,៦៤% (អាណត្តិទី៣ ឆ្នាំ២០១២)។

## តារាង ទី១ : ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ទាំង១០គណបក្ស

| ល.រ | ឈ្មោះគណបក្ស | បេក្ខជនស្ត្រីឈរឈ្មោះ (ពេញសិទ្ធិ) | | | | | | | | ចំនួនឃុំសង្កាត់ |
|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនសរុប | % | ឈរឈ្មោះល.រទី១ | % | ឈរឈ្មោះល.រទី២ | % | ឈរឈ្មោះល.រទី៣ | % | |
| ១ | ប្រជាជនកម្ពុជា | ៦០៦៩ | ២២,៤៦ | ៩៣ | ៥,៦៩ | | | | | ១៦៣៣ |
| ២ | សម រង្ស៊ី | ៥១៤៦ | ២០,៧៤ | ១២៤ | ៧,៦៤ | ១៩៦ | ១២,០៩ | ២៨៣ | ១៧,៤៥ | ១៦២១ |
| ៣ | ហ៊្វុនស៊ិនប៉ិច | ៦៣០៦ | ៣០,៦៨ | ១១៩ | ៨,១៩ | | | | | ១៤៥២ |
| ៤ | សិទ្ធិមនុស្ស | ៣៤៦១ | ២១,៣៣ | ៥១ | ៤,៥២ | | | | | ១១២៨ |
| ៥ | នរោត្តម រណឫទ្ធិ | ៤៧៥២ | ៣០,៣២ | ៧៧ | ៧,៤១ | | | | | ១០៣៩ |
| ៦ | សញ្ជាតិកម្ពុជា | ១៨១៦ | ៥០,៥៧ | ២៩ | ៧,៨១ | | | | | ៣៧១ |
| ៧ | សម្ពន្ធ័ដើម្បីប្រជាធិបតេយ្យ | ៧៤៦ | ២៧,៤៩ | ៥ | ៣,០៣ | | | | | ១៦៥ |
| ៨ | ខ្មែរឈប់ក្រ | ១១០ | ៣២.៩៣ | ២ | ៨,៣៣ | | | | | ២៤ |
| ៩ | សាធារណរដ្ឋប្រជាធិបតេយ្យ | ៦៦ | ៤៦,៨០ | ១ | ៩,០៩ | | | | | ១១ |
| ១០ | ចលនាប្រជាធិបតេយ្យ | ៩ | ៣៧,៥០ | ០ | | | | | | ៣ |
| សរុប | ១០ គណបក្ស | ២៨៤៨១ | ២៥,៦៤ | ៥០១ | ០,៤៥ | | | | | |

តារាងទី១ បង្ហាញថា មានបេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ចំនួនតិចតួចបំផុត គឺ **៥០១នាក់** (**០,៤៥%**)នៃបេក្ខជនសរុបចំនួន ១១១ ០៥៦នាក់ ក្នុងនោះគណបក្សដែលមានអាសនៈនៅក្នុងសភា ចំនួនស្ត្រីឈរឈ្មោះនៅលេខរៀងទី១មានការកើនឡើងតិចតួច ដូចជា គណបក្សប្រជាជនកម្ពុជាពី៤,០៧%ក្នុងអាណត្តិទី២ ឆ្នាំ២០០៧ ទៅ ៥,៦៩%ក្នុងអាណត្តិទី៣ ឆ្នាំ២០១២។ គណបក្សសម រង្ស៊ីពី ៥,៩២%ក្នុងអាណត្តិទី២ ឆ្នាំ២០០៧ ទៅ ៧,៦៤%ក្នុងអាណត្តិទី៣ ឆ្នាំ២០១២។ គណបក្សហ៊្វុនស៊ិនប៉ិចពី ៥,៩២%ក្នុងអាណត្តិទី២ ឆ្នាំ២០០៧ ទៅ ៨,១៩% ក្នុងអាណត្តិទី៣ ឆ្នាំ២០១២។ គណបក្សនរោត្តម រណឫទ្ធិ ពី

៤,៨១%ក្នុងអាណត្តិទី២ ឆ្នាំ២០០៧ ទៅ ៧,៤១%ក្នុងអាណត្តិទី៣ ឆ្នាំ២០១២ និងគណបក្សសិទ្ធិមនុស្សដែលទើបតែចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឃុំអាណត្តិទី៣នេះ មានចំនួនតែ ៤,៥២% ប៉ុណ្ណោះ។ ចំណែកឯបេក្ខជនស្ត្រីឈរឈ្មោះនៅ**លំដាប់លេខរៀងចាប់ពីទី១ ដល់ ទី៣មានចំនួនប៉ុន្មាន** យើងពុំអាចធ្វើការប្រៀបធៀបបានទេដោយសារគ.ជ.បពុំព្រមផ្តល់តួលេខដល់អង្គការសង្គមស៊ីវិល ទោះបីមានការស្នើសុំជាលាយលក្ខណ៍អក្សរក៏ដោយ។ ជាក់ស្តែង ខុមហ្វ្រែលបានដាក់សំបុត្រស្នើសុំតួលេខបេក្ខជនស្ត្រីឈរឈ្មោះចំនួន២ដងទៅគ.ជ.ប កាលពីថ្ងៃទី១៩ ខែឧសភា ស្នើសុំ "**ការបូកសរុបចំនួនបេក្ខនារី (ទាំងតួលេខ និងភាគរយ) របស់គណបក្សទាំង១០ពីលេខរៀងទី១ដល់ទី៣**" និងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ស្នើសុំ " **សៀវភៅបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣របស់គណបក្សទាំង១០** "ក្នុងគោលបំណងធ្វើការប្រៀបធៀបពីអាណត្តិមួយទៅអាណត្តិមួយថាតើមានការកើនឡើង ឬថយចុះដើម្បីរកមធ្យោបាយថ្មីៗក្នុងការលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ។

គួរកត់សម្គាល់ថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣នេះ គណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) និងគណបក្សប្រឆាំង២ គឺ គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានដាក់បេក្ខជនស្ត្រីឈរឈ្មោះតិចជាងគេដែលសុទ្ធសឹងជាគណបក្សមានប្រជាប្រិយភាពខ្លាំង។ ជាក់ស្តែង គណបក្សសម រង្ស៊ីមានបេក្ខជនស្ត្រីចំនួន២០,៧៤% គណបក្សសិទ្ធិមនុស្សមានបេក្ខជនស្ត្រីចំនួន២១,៣៣% និងគណបក្សប្រជាជនកម្ពុជាមានបេក្ខជនស្ត្រីចំនួន២២,៤៦%។ ចំណែកឯគណបក្សដែលពុំសូវមានប្រជាប្រិយភាពបានខិតខំដាក់បេក្ខជនស្ត្រីឈរឈ្មោះច្រើន ដូចជា គណបក្សហ៊្វុនស៊ិនប៉ិចមានបេក្ខជនស្ត្រីចំនួន៣០,៦៨% គណបក្សនរោត្តម រណឫទ្ធិមានបេក្ខជនស្ត្រីចំនួន៣០,៣២% គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមានបេក្ខជនស្ត្រីចំនួន២៧,៤៩% គណបក្សខ្មែរឈប់ក្រមានបេក្ខជនស្ត្រីចំនួន៣២,៩៣% គណបក្សចលនាប្រជាធិបតេយ្យមានបេក្ខជនស្ត្រីចំនួន៣៧,៥០% គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យមានបេក្ខជនស្ត្រីចំនួន៤៦,៨០% និងគណបក្សសញ្ជាតិកម្ពុជាមានបេក្ខជនស្ត្រីចំនួន៥០,៥៧%។ គួរកត់សម្គាល់ផងដែរ ចំនួនបេក្ខជនស្ត្រីនៅតំបន់ទីក្រុងមានភាគរយច្រើនជាងនៅតាមបណ្តាខេត្ត ជាពិសេសបេក្ខជនស្ត្រីនៅទីក្រុងភ្នំពេញឡើងដល់៣៨,២៧% ទីក្រុងប៉ៃលិនចំនួន៣៣% និងទីក្រុងកែបចំនួន៣០%។ ។ *(សូមមើលឧបសម្ព័ន្ធ ១ ស្តីពី ចំនួនបេក្ខជនស្ត្រីឈរឈ្មោះតាមខេត្ត)*

ទោះបីចំនួនបេក្ខជនស្ត្រីឈរឈ្មោះមានការកើនឡើងពីអាណត្តិមួយទៅអាណត្តិមួយក៏ដោយ ក៏តួលេខនេះនៅតែជាចំនួនតិចតួច ពិសេសស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើនៃបញ្ជីបេក្ខជនគណបក្សនយោបាយបើប្រៀបធៀបនឹងចំនួនបេក្ខជនសរុប (បុរស-ស្ត្រី) ១១១ ០៥៦នាក់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិទី៣នេះ។ តួលេខនេះបង្ហាញឱ្យឃើញថា កម្ពុជាមានបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិ និងអំណាចនយោបាយរវាងបុរស និងស្ត្រី។

យោងតាមរបាយការណ៍វាយតម្លៃរបស់ខុមហ្វ្រែលស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២ ស្ត្រីនៅតែភ័យខ្លាចក្នុងការភ្ជាប់ខ្លួនជាមួយនឹងគណបក្សប្រឆាំងក្រោយមានអំពើហឹង្សាខ្លះបានកើតឡើងប្រឆាំងនឹងស្ត្រីដែលជំទាស់នឹងរដ្ឋាភិបាល។ មានបេក្ខជនស្ត្រី និងគណបក្សនយោបាយជាច្រើនបានឱ្យអ្នកសង្កេតការណ៍ដឹងថា ការរើសអើងប្រឆាំងនឹងបេក្ខជនស្ត្រីដែលពួកគេជួបប្រទះ គឺក្នុងពេលដំណើរការតែងតាំងបេក្ខជន និងការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្ស។

គណបក្សនយោបាយមួយចំនួន បានលើកឡើងអំពីការប្រឈមក្នុងការរកស្ត្រីមានសមត្ថភាពក្នុងកិច្ចការនយោបាយ និងការងារបោះឆ្នោត។ ប៉ុន្តែជាក់ស្តែង បើទោះបីជាស្ត្រីជាច្រើនត្រូវបានបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំក្នុងកិច្ចការនយោបាយ និងការងារបោះឆ្នោតដោយអង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលបានបញ្ជូនបញ្ជីឈ្មោះស្ត្រីជាច្រើននាក់ដែលខ្លួនបានបណ្តុះបណ្តាល និងហ្វឹកហាត់រួចទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងសភាដើម្បីឈរឈ្មោះជាបេក្ខជន។ គណបក្សនយោបាយបានទទួលយកស្ត្រីទាំងនោះទៅឈរឈ្មោះឱ្យបានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ បានតែ១/៣នៃចំនួនស្ត្រីបានទទួលការហ្វឹកហ្វឺន។ ជាក់ស្តែងខុមហ្វ្រែលបានបញ្ជូនបញ្ជីឈ្មោះស្ត្រី ចំនួន៥៤០នាក់ ប៉ុន្តែជាលទ្ធផល គណបក្សបានឱ្យស្ត្រីទាំងនោះឈរឈ្មោះចំនួនតែ ១៤៨នាក់ (២៧,៤០%)។ ដូចគ្នានេះ អង្គការអមរាបានបណ្តុះបណ្តាលសកម្មជននយោបាយស្ត្រី ២០៧នាក់ តែមាន៩៦នាក់ (៤៦,៣៧%) បានឈរឈ្មោះ និងជាប់ឆ្នោត។ កត្តាផ្សេងទៀតត្រូវបានរកឃើញថា ការជ្រើសបេក្ខជនស្ត្រីនៅជួរលើនៃបញ្ជីបេក្ខជនឈរឈ្មោះ គឺជាការប្រឆាំងទៅនឹងបេក្ខភាពបុរស។ ជាងនេះទៅទៀត បរិយាកាសនយោបាយក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោតម្តងៗ គេសង្កេតឃើញមានការគំរាមកំហែង និងបញ្ហាជាច្រើនទៀតដែលធ្វើឱ្យមានឥទ្ធិពលជាអវិជ្ជមានដល់ស្ត្រី និងធ្វើឱ្យពួកគេរារែកក្នុងការចូលរួមក្នុងនយោបាយ។

គណបក្សខ្លះយល់ថា ការដាក់បេក្ខភាពមេឃុំ ចៅសង្កាត់ជាស្ត្រី គឺពុំសូវទាក់ទាញអ្នកបោះឆ្នោត ព្រោះអាចមិនមែនជាទម្លាប់ជម្រើសរបស់ប្រជាពលរដ្ឋខ្មែរទេ។ ការទុកចិត្តទៅលើស្ត្រីជាមេឃុំអាចនៅមានកម្រិតក្នុងការគ្រប់គ្រងបញ្ហាសន្តិសុខ និងភាពជាអ្នកដឹកនាំឃុំ សង្កាត់។ គណបក្សនយោបាយខ្លះ ដូចជា គណបក្សសិទ្ធិមនុស្សបានលើកឡើងអំពីការជ្រើសរើសបេក្ខជន ឬបេក្ខនារីសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយតាមគោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុង ដែលសមាជិកគណបក្សតាមមណ្ឌលឃុំ សង្កាត់នីមួយៗជាអ្នកបោះឆ្នោតទុកចិត្តបេក្ខភាពទាំងនោះសម្រាប់បញ្ជីបេក្ខជននៃគណបក្សរបស់ខ្លួន។ ការប្រើប្រាស់គោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងគណបក្សក៏បានបង្កើតការប្រឈមមួយសម្រាប់បេក្ខភាពនារី ដែលសមាជិកបក្សមិនបានទុកចិត្តបោះជូនបេក្ខភាពនារី។ ហេតុដូចនេះ គណបក្សសិទ្ធិមនុស្សមានបេក្ខនារីជាប់ឆ្នោតនៅបញ្ជីខាងលើតិចបំផុត ១,៥០% (១២នាក់) នៃចំនួនអ្នកជាប់ឆ្នោតសរុប ៨០០នាក់។ គណបក្សប្រជាជនកម្ពុជា ក៏មានដំណើរការជ្រើសរើសបេក្ខភាពសម្រាប់បញ្ជីបេក្ខជននៃគណបក្សតាមគោលការណ៍ការបោះឆ្នោតពីសមាជិកខ្លួននៅមណ្ឌលឃុំ សង្កាត់នីមួយៗ ប៉ុន្តែលទ្ធផលនៃការបោះឆ្នោតនោះមិនបានបង្ហាញនៅថ្នាក់ឃុំ សង្កាត់ឱ្យសមាជិកជាអ្នកបោះឆ្នោតបានដឹងទេ។ លទ្ធផលនៃការបោះឆ្នោតត្រូវបានពិនិត្យ ហើយ

សម្រេចរើសបេក្ខជន និងបេក្ខនារីដាក់ក្នុងបញ្ជីបេក្ខជននៃគណបក្សនៅគណបក្សថ្នាក់លើយ៉ាងហោចនៅកម្រិតថ្នាក់ស្រុក ខណ្ឌ។ ចំណែកគណបក្សសម រង្ស៊ីបានផ្តល់ការសម្រេចក្នុងការជ្រើសរើសបេក្ខភាពទៅគណបក្សថ្នាក់មូលដ្ឋាន ប៉ុន្តែមានការអន្តរាគមន៍ពីថ្នាក់ដឹកនាំចលនាស្ត្រីចំពោះការជ្រើសរើសបេក្ខជន-បេក្ខនារីសម្រាប់បញ្ជីបេក្ខជននៃគណបក្ស។ នីតិវិធីដោយមានអន្តរាគមន៍ពីរចនាសម្ព័ន្ធគណបក្សថ្នាក់លើរួមទាំងគោលនយោបាយ ក៏អាចបង្កើនចំនួនបេក្ខនារីដែលអាចជាប់ឆ្នោតបានច្រើន ដូចជាគណបក្សប្រជាជនកម្ពុជា និងគណបក្សសម រង្ស៊ី។ ជាក់ស្តែង **លោកជំទាវ មូរ សុខហួរ** តំណាងរាស្ត្រគណបក្សសម រង្ស៊ីបានពន្យល់ពីករណីមេឃុំស្ត្រីជាប់ឆ្នោតថ្មី **កញ្ញា តឹក នីម** ថា គណបក្សសម រង្ស៊ី គឺមានចេតនាផ្តល់ឱកាសដល់កញ្ញា តឹក នីម ជាបេក្ខភាពលេខរៀងទី១ក្នុងបញ្ជីបេក្ខជននៃគណបក្ស។ កញ្ញា តឹក នីម បានជាប់ឆ្នោតជាមេឃុំស្ត្រីវ័យក្មេងនៅឃុំដែលមានទំនាស់ដីធ្លីច្រើន និងភ្ញាក់ផ្អើល (ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ)បើទោះបីជា កញ្ញា តឹក នីមគ្មានបទពិសោធក្នុងកិច្ចការនយោបាយ និងមនុស្សប្រុសនៅទីនោះមានពិសោធន៍ខាងនយោបាយក៏ដោយ។ (នេះបើយោងតាមកិច្ចពិភាក្សាតុមូល ស្តីពីភាពជោគជ័យ និងការប្រឈមរបស់ស្ត្រីចំពោះលទ្ធផលបោះឆ្នោតឃុំ សង្កាត់ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២)។

**លោក យឹម សុវណ្ណ** មន្ត្រីនាំពាក្យគណបក្សសម រង្ស៊ី បានមានប្រសាសន៍ថា *"យើងចង់ជំរុញឱ្យបានដល់៣០% ក៏ប៉ុន្តែដោយសារលក្ខខណ្ឌសង្គម ការលំបាក ភាពក្រីក្រ ការគំរាមកំហែង ការរើសអើង ដែលធ្វើឱ្យបន្ថយបង្អាក់ទៅដល់ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចការនយោបាយ។ អញ្ចឹងហើយ យើងត្រូវជំនះឱ្យបានការគំរាមកំហែងទាំងអស់ដែលធ្វើឱ្យស្ត្រីមិនអាចចូលរួមតាមអ្វីដែលយើងចង់បានទេ មិនត្រឹមតែយើងចង់បានតែប៉ុណ្ណឹងទេយ៉ាងតិច៣០%នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់"*។ ការផ្សាយរបស់វិទ្យុអាស៊ីសេរី នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២

អគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស **លោក ញ៉ែម បុញ្ញឫទ្ធិ** បានឱ្យដឹងដែរថា *" យើងឃើញថា ជាការល្អមែនទែនដែលមានស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់។ ហើយជាលើកទី១ដែលយើងរៀបចំ ហើយយើងនឹងព្យាយាមជំរុញលើកទឹកចិត្តឱ្យស្ត្រីចូលរួមដើម្បីដោះស្រាយបញ្ហាសង្គមជាមួយយើងតទៅទៀត។..."*។ ការផ្សាយរបស់ វិទ្យុអាស៊ីសេរី នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២

នាយកប្រតិបត្តិអង្គការខុមហ្វ្រែល **លោក គល់ បញ្ញា** បានមានប្រសាសន៍ថា *" របៀបធ្វើកិច្ចការបក្សរបស់គេហ្នឹង ដើម្បីឱ្យបានដាក់ស្ត្រីនៅក្នុងបញ្ជីនេះ ឃើញមានការខិតខំរបស់គណបក្សនយោបាយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គណបក្សនយោបាយមិនទាន់មានជាគោលនយោបាយ ឬក៏ជាច្បាប់ទម្លាប់ផ្ទៃក្នុងបក្សហ្នឹងច្បាស់លាស់អំពីការពិនិត្យមើលដាក់ឱ្យស្ត្រីហ្នឹងទៅតាមចំនួនមួយពិតប្រាកដឱ្យបានច្បាស់លាស់ ប៉ុន្តែស៊ីសងទៅលើថ្នាក់ដឹកនាំគណបក្សហ្នឹង"*។ ការផ្សាយរបស់ វិទ្យុអាស៊ីសេរី នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២

អគ្គលេខាធិការគណៈកម្មាធិកាជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) **លោក ទេព នីថា** បានមានប្រសាសន៍ថា *"មូលហេតុដែលគណបក្សនយោបាយមានការកើនឡើងនូវបេក្ខភាពជាស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ គឺដោយសារគណបក្សនីមួយៗ បាន*

*យកចិត្តទុកដាក់ក្នុងការឈរឈ្មោះក្នុងបញ្ជីបេក្ខភាពបោះឆ្នោត ដាក់ជាលំដាប់លេខរៀងសម្រាប់បេក្ខជនជាប់ឆ្នោតនោះភាគច្រើនជាស្ត្រី"* ។ ការផ្សាយរបស់ វិទ្យុអាស៊ីសេរី នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២

## ១.២ ស្ត្រីជាប់ឆ្នោត

### តារាងទី ២ : ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

| គណបក្ស | ស្ត្រីជាប់ឆ្នោតអាណត្តិទី៣ | | | | | | | | | | អាសនៈទទួលបាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនសរុប | % | មេឃុំ ចៅសង្កាត់ | | ជំទប់ទី១ | | ជំទប់ទី២ | | សមាជិក | | |
| | | | # | % | # | % | # | % | # | % | |
| ប្រជាជនកម្ពុជា | ១ ៧៨១ | **២១,៤៨** | ៩៣ | **៥,៨៤** | ១៧១ | **១៦,១៩** | ៧៤ | **២៩,៦០** | ១ ៤៤៣ | **២៦,៧៥** | ៨ ២៩២ |
| សម រង្ស៊ី | ២៣៧ | **១១** | ២ | **៩,០៩** | ១៦ | **៤,៦៩** | ៨១ | **៨,៤៨** | ១៣៨ | **១៦,៤៨** | ២ ១៥៥ |
| សិទ្ធិមនុស្ស | ១២ | **១,៥០** | ០ | **០** | ១ | **០,៤៩** | ៥ | **១,៦២** | ៦ | **២,២០** | ៨០០ |
| ហ៊្វុនស៊ិនប៉ិច | ៥ | **៣,៣១** | ០ | **០** | ០ | **០** | ៣ | **៣,៤៨** | ២ | **៥,៨៨** | ១៥១ |
| នរោត្តម រណឬទ្ធិ | ៣ | **៥,៧៧** | ០ | **០** | ១ | **២០** | ១ | **៤,១៦** | ១ | **៤,៣៤** | ៥២ |
| សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | | | | | | | | | | | ៨ |
| សញ្ជាតិកម្ពុជា | | | | | | | | | | | ១ |
| **សរុបរួម** | **២ ០៣៨** | **១៧,៧៨** | **៩៥** | **៥,៨១** | **១៨៩** | **១១,៥៧** | **១៦៤** | **១០,០៤** | **១៥៩០** | **២៤,២៣** | **១១ ៤៥៩** |

តារាងទី២បង្ហាញលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ថា បេក្ខជនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនតែ **២០៣៨នាក់**(**១៧,៧៨%**)នៃចំនួនអ្នកជាប់ឆ្នោតសរុប ១១ ៤៥៩នាក់។ គណបក្សចំនួន៥ដែលមានស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ គឺ គណបក្សប្រជាជនកម្ពុជា **២១,៤៨%**(១៧៨១នាក់)ដែលជាភាគរយខ្ពស់បំផុតក្នុងចំណោមគណបក្សទាំងអស់។ បេក្ខជនស្ត្រីនៃគណបក្សប្រឆាំងធំ គណបក្សសម រង្ស៊ីបានជាប់ឆ្នោតភាគរយទីពីរ គឺ **១១%** (២៣៧នាក់)។ គណបក្សពាផ្សេងទៀត ស្ត្រីជាប់ឆ្នោតមានចំនួនតិចតួចរាប់បញ្ចូលគណបក្សនរោត្តម រណឬទ្ធិ ទទួលបាន **៥,៧៦%**(៣នាក់) គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន **៣,៣១%** (៥នាក់) ចំណែកឯគណបក្សសិទ្ធិមនុស្សជាគណបក្សប្រឆាំងទីពីរ

បានដាក់ស្ត្រីឱ្យជាប់ឆ្នោតបានតែ**១,៥%**(១២នាក់)នៃចំនួនសរុប៨០០ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងចំណោមស្ត្រីជាប់ឆ្នោត មេឃុំ ចៅសង្កាត់ស្ត្រីមានចំនួន **៩៥នាក់** (**៥,៨១%**)នៃមេឃុំ ចៅសង្កាត់សរុប ១៦៣៣ឃុំ សង្កាត់ (គណបក្សប្រជាជនកម្ពុជា ៩៣នាក់ និងគណបក្សសម រង្ស៊ី ២នាក់)។ ស្ត្រីជាជំទប់ទី១/ចៅ សង្កាត់រងទី១សរុបចំនួន**១៨៩នាក់** ស្មើនឹង **១១,៥៧%** (គណបក្សប្រជាជនកម្ពុជា១៧១នាក់ គណបក្សសម រង្ស៊ី១៦នាក់ គណបក្សសិទ្ធិមនុស្ស១នាក់ និងគណបក្សនរោត្តម រណឫទ្ធិ ១នាក់ )។ ស្ត្រីជាជំទប់ទី២/ចៅសង្កាត់រងទី២សរុបចំនួន **១៦៤នាក់** ស្មើនឹង **១០,០៤%** (គណបក្សប្រជាជនកម្ពុជា៧៤នាក់ គណបក្សសម រង្ស៊ី៨១នាក់ គណបក្សសិទ្ធិមនុស្ស៥នាក់ គណបក្សហ៊្វុនស៊ិនប៉ិច៣នាក់ និងគណបក្សនរោត្តម រណឫទ្ធិ១នាក់)។ ស្ត្រីជាសមាជិកសរុបចំនួន**១៩៩០នាក់** ស្មើនឹង **២៤,២៣%** (គណបក្សប្រជាជនកម្ពុជា១៤៤៣នាក់ គណបក្សសម រង្ស៊ី១៣៩នាក់ គណបក្សសិទ្ធិមនុស្ស៤នាក់ គណបក្សហ៊្វុនស៊ិនប៉ិច២នាក់ និងគណបក្សនរោត្តម រណឫទ្ធិ២នាក់)។ លទ្ធផលបោះឆ្នោតបានបង្ហាញថា ខេត្តប៉ៃលិន និងរាជធានីភ្នំពេញមានចំនួនស្ត្រីជាប់ឆ្នោតច្រើន ដោយឡែកខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យក៏បានចំនួនភាគរយក្រុមប្រឹក្សាស្ត្រីជិតដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែរ ។*(សូមមើលឧបសម្ព័ន្ធ ២ ស្តីពី ចំនួនស្ត្រីជាប់ឆ្នោតតាមខេត្ត)*

បើប្រៀបធៀបនឹងអាណត្តិទី២ ចំនួនស្ត្រីជាប់ឆ្នោតមានការកើនឡើងតិចតួច **៣,១៤%** (៣៧៦នាក់)ពី **១៦៦២នាក់** ស្មើនឹង **១៤,៦៤%** (អាណត្តិទី២ ឆ្នាំ២០០៧ជាប់ឆ្នោតភ្លាម) ទៅ **២០៣៨នាក់** ស្មើនឹង **១៧,៧៨%** (អាណត្តិទី៣ ឆ្នាំ២០១២ជាប់ឆ្នោតភ្លាម) និងមានការកើនឡើងមេឃុំស្ត្រី**១,៦៨%** ពី **៤,១៣%** (**៦៧នាក់**)នៅអាណត្តិទី២ ទៅ **៥,៨១%**(**៩៥នាក់**)នៅអាណត្តិទី៣។ តួលេខនេះបង្ហាញថា កម្ពុជានៅមានការប្រឈមក្នុងការធ្វើឱ្យបានសម្រេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(CMDG) ដែលកម្ពុជាបានកំណត់ថា នៅឆ្នាំ២០១៥មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ឃុំ សង្កាត់យ៉ាងតិច២៥%។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជានៅសល់ពេលវេលាខ្លះក្នុងការធ្វើឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នេះ ព្រោះថារយៈពេល៣ឆ្នាំទៀត (ឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៥) រាជរដ្ឋាភិបាលអាចខិតខំបង្កើនចំនួនស្ត្រីតាមមធ្យោបាយផ្សេងៗតាមដែលអាចធ្វើទៅបាន ដូចជា ដាក់ស្ត្រីជំនួសបុរសដែលលាលែងពីតំណែង ដាក់ស្ត្រីជំនួសស្ត្រីដែលបានលាលែងពីតំណែង។ល។ (ករណីសន្មត់ថា រាជរដ្ឋាភិបាលប្តេជ្ញាចិត្តធ្វើឱ្យបានសម្រេចជោគជ័យតាមCMDG)។ ក្រៅពីខិតខំប្រឹងប្រែងបង្កើនចំនួនស្ត្រី ការយកចិត្តលើគុណភាពនៃការចូលរួមរបស់ស្ត្រីក៏ជារឿងសំខាន់ណាស់ដែរ ធ្វើយ៉ាងណាឱ្យស្ត្រីមានសំលេងក្នុងការសម្រេចចិត្ត និងបំពេញការងារដោយគ្មានការរើសអើងពីសំណាក់បុរសដែលជាសហការី។

## រូបភាពក្រាហ្វិក ១ : មេឃុំ ចៅសង្កាត់ស្ត្រី




ក្រាហ្វិក១បង្ហាញថា ក្នុងចំណោមមេឃុំ ចៅសង្កាត់ស្ត្រី៩៥នាក់ មានស្ត្រីមេឃុំ ចៅសង្កាត់**ថ្មីចំនួន៤៨នាក់** ស្មើនឹង ៥០,៥២%នៃមេឃុំ ចៅ សង្កាត់ស្ត្រី [*ស្ត្រីវ័យក្មេងមានចំនួន៨នាក់(៨,៤២%នៃមេឃុំ ចៅសង្កាត់ស្ត្រី) និងស្ត្រីវ័យចំណាស់មានចំនួន៤០នាក់(៤២,១០%នៃ មេឃុំ ចៅសង្កាត់ស្ត្រី)*] មេឃុំស្ត្រីនៅឃុំ**ដាច់ស្រយាលមានចំនួន១៦នាក់** (១៦,៨៤%នៃមេឃុំស្ត្រី) *និង*មេឃុំស្ត្រីជា**ជនជាតិដើមភាគតិចមានចំនួន៥នាក់** (៥,២៦%នៃមេឃុំស្ត្រី)។ គួរកត់សម្គាល់ថា ខេត្តដែលមានស្ត្រីមេឃុំ ចៅសង្កាត់ច្រើនជាងគេ ដូចជា ខេត្តកណ្តាលចំនួន១៤នាក់ ខេត្តកំពង់ចាមចំនួន១២នាក់ ក្រុងភ្នំពេញចំនួន១១នាក់ និងខេត្តកំពង់ឆ្នាំងចំនួន៧នាក់។ ភាគរយស្ត្រីជាមេឃុំ ចៅសង្កាត់មានចំនួនតិចតួចណាស់នៃមេឃុំ ចៅសង្កាត់សរុប ១៦៣៣ឃុំ សង្កាត់។ យោងតាមការសិក្សាស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលរកឃើញថា តួនាទីស្ត្រីជាមេឃុំ/ចៅសង្កាត់ធ្វើការមានសិទ្ធិអំណាចពេញលេញ និងធ្វើការមានប្រសិទ្ធភាពជាងស្ត្រីដែលមានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ *។(សូមមើលឧបសម្ព័ន្ធ ៣ ស្តីពី មេឃុំ ចៅសង្កាត់ស្ត្រី)*

ការបោះឆ្នោតលើកនេះ យើងឃើញមានការផ្លាស់ប្តូរបែបវិជ្ជមានខ្លះពីការចូលរួមរបស់ស្ត្រី។ ជាក់ស្តែង កញ្ញា **តឹក នីម ពីប្រជាពលរដ្ឋសាមញ្ញដែលរងគ្រោះដោយវិវាទដីធ្លីបានក្លាយទៅជាមេឃុំ។ កញ្ញាតឹក នីម** មានអាយុ២៧ ជាពលរដ្ឋរងគ្រោះម្នាក់ក្នុងចំណោមពលរដ្ឋរាប់ពាន់នាក់ក្នុងឃុំអមលាំង ដែលមានវិវាទដីធ្លីដ៏រ៉ាំរ៉ៃជាមួយក្រុមហ៊ុនស្ករសភ្នំពេញ បានឈ្នះឆ្នោតក្លាយ

ជា**មេឃុំស្ត្រីវ័យក្មេង**នៅក្នុង**ឃុំអមលាំង** ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលកញ្ញាចាប់ផ្ដើមចូលរួមជាមួយគណបក្សសម រង្ស៊ីនៅឆ្នាំ២០១០ នៅពេលកញ្ញា និងអ្នកភូមិចាប់ផ្ដើមមានបញ្ហាដីធ្លីជាមួយក្រុមហ៊ុនស្ករសភ្នំពេញដែលនៅក្នុងឃុំអមលាំងនេះ មានភាពចំរូងចំរាស់ទាក់ទងនឹងដីធ្លី ការគាបសង្កត់ និងបំភិតបំភ័យពីក្រុមជើងកាងមកលើប្រជាពលរដ្ឋ និងកន្លងមកជាការគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា។ ចំណុចវិជ្ជមានមួយទៀត បេក្ខនារីចំនួន១៧៤នាក់ដែលខុមហ្វ្រែលបានធ្វើការបណ្ដុះបណ្ដាលនៅក្នុងតំបន់គោលដៅចំនួន៥ខេត្តបានជាប់ឆ្នោតចំនួន**៩២នាក់ (៥៣%)**។ ដូចគ្នានេះ បេក្ខនារីចំនួន៩៦នាក់ដែលអង្គការអមរាបានធ្វើការបណ្ដុះបណ្ដាលនៅក្នុងខេត្តបាត់ដំបងបានជាប់ឆ្នោតទាំងអស់**៩៦នាក់(១០០%)** ក្នុងនោះមានជា មេឃុំ ជំទប់ទី១ ជំទប់ទី២ និងសមាជិក។

## ករណីសិក្សាទី ១ : អតីតមេឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម



លោកស្រី យ៉ាសឿន ចុះផ្សព្វផ្សាយពីអំពើហឹង្សាដល់ប្រជាពលរដ្ឋភូមិត្រកួន ឃុំក្រឡា

**"ខ្ញុំចង់បំរើការងារជូនប្រជាពលរដ្ឋក្នុងឃុំក្រឡាណាស់ តែខ្ញុំមិនអាច ធ្វើការងារមមាញឹកច្រើនបាន"** នេះជាឆន្ទៈរបស់**លោកស្រី យ៉ា សឿន** អតីតមេឃុំ ក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ជាបេក្ខភាពគណបក្សប្រជាជនកម្ពុជា។

អតីតមេឃុំក្នុងវ័យ**៦៧ឆ្នាំ**រូបនេះបានរៀបរាប់ថា" *និយាយដោយស្មោះ ខ្ញុំចង់ឈប់ធ្វើការណាស់ តែប្រជាពលរដ្ឋក្នុងឃុំហ្នឹងហាំអត់ចង់ឱ្យខ្ញុំឈប់ ហើយនាំគ្នានិយាយថា បើខ្ញុំឈប់ធ្វើការក្នុងឃុំ គេក៏ឈប់បោះឆ្នោតគាំទ្រគណបក្សខ្ញុំដែរ។ ហេតុដូចនេះ ខ្ញុំសម្រេចចិត្តឈរឈ្មោះបោះឆ្នោត តែសុំឈរលេខរៀងទី២ ឬទី៣វិញ ព្រោះខ្ញុំចាស់ហើយខ្ញុំមិនអាចធ្វើការងារច្រើន មិនអាចជិះកង់ទៅឆ្ងាយៗបានដូចមុន ខ្ញុំចង់ឱ្យក្មេងៗដែលមានប្រាជ្ញា កំលាំង និងរហ័សរហួនបំរើប្រជាពលរដ្ឋវិញ។ ប៉ុន្តែគួរឱ្យស្ដាយប្រជាពលរដ្ឋខ្លះឈប់បោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជាមែន ដោយសារខ្ញុំមិនឈរឈ្មោះជាមេឃុំ"* ។ លោកស្រី បានចែករំលែកបទពិសោធន៍ក្នុងការទាក់ទាញទឹកចិត្តប្រជាពលរដ្ឋថា ***"ដើម្បីរូបយើងស្ថិតក្នុងចិត្តរបស់ប្រជាពលរដ្ឋ គឺយើងត្រូវតែស្មោះត្រង់ យកចិត្តទុកដាក់ មិនពុករលួយ និងផ្ដល់យុត្តិធម៌ដល់ពួកគាត់"***។ ដូចជារូបខ្ញុំអញ្ចឹង សំខាន់គឺខ្ញុំយកចិត្តទុកដាក់ធ្វើការ ហើយខ្ញុំមិនដែលទារលុយពីប្រជាពលរដ្ឋទេពេលដែលគាត់សុំឱ្យខ្ញុំចុះហត្ថលេខាលើឯកសារផ្សេងៗ និងពេលដែលប្រជាពលរដ្ឋមានបញ្ហា ខ្ញុំជិះកង់ទៅភ្លាម ទោះជាភូមិឆ្ងាយក៏ដោយ។

តាមប្រសាសន៍របស់ **លោកស្រី សា វឿន** ជាប្រជាពលរដ្ឋរស់នៅភូមិឫស្សី ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានបញ្ជាក់ថា" *ខ្ញុំសប្បាយរីករាយដែលបានអ៊ីសឿនធ្វើជាមេឃុំ ព្រោះគាត់ធ្វើការបានល្អ ពេលទៅស៊ីញ៉េម្ដងៗគាត់មិនដែលយកលុយកាក់អីទេ ខ្ញុំចង់ឱ្យគាត់ធ្វើជាមេឃុំបន្តទៀត*"។ ចំណែកលោកស្រី**ជិន ស្រេង** ជាប្រជាពលរដ្ឋរស់នៅភូមិត្រពាំងជ្រៃ ឃុំក្រឡា

បានសំដែងទឹកចិត្តរបស់គាត់ថា *"ខ្ញុំយល់ឃើញថា លោកស្រីធ្វើការល្អទាំងការជួយដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការផ្សព្វផ្សាយអំពីយេនឌ័រ សុខភាពមាតា និងទារក។ មិនតែប៉ុណ្ណោះគាត់បានទំនាក់ទំនងជាមួយអង្គការនានា ដើម្បីសុំជំនួយមកធ្វើផ្លូវថ្នល់ និងអណ្តូងទឹក។ ខ្ញុំមិនចង់ឱ្យគាត់ឈប់ធ្វើជាមេឃុំទេ"*។

សព្វថ្ងៃ ទោះបីលោកស្រីជាសមាជិកក្រុមប្រឹក្សាក៏ដោយ ក៏លោកស្រីនៅតែចុះតាមភូមិ និងដាស់តឿនមេឃុំថ្មី ស្មៀនឃុំឱ្យចុះជាប់ជាមួយប្រជាពលរដ្ឋ។ លោកស្រីមានប្រសាសន៍បន្ថែមទៀតថា ក្នុងកម្មវិធីប្រគល់ដំណែងទៅមេឃុំថ្មី ខ្ញុំបានផ្តាំផ្ញើដល់មេឃុំថ្មី និងសមាជិកក្រុមប្រឹក្សាទាំងអស់ថា *"ទាំងអស់គ្នាត្រូវគិតប្រជាពលរដ្ឋក្នុងឃុំជាធំ"*។ លោកស្រីបន្ត *"ពួកគេស្តាប់ខ្ញុំជាពិសេសមេឃុំថ្មី និងស្មៀនឃុំចុះត្រួតពិនិត្យប្រជាពលរដ្ឋតាមភូមិជាប្រចាំ"*។

សូមបញ្ជាក់ថានៅឆ្នាំ១៩៧៩-១៩៨០ **លោកស្រី យ៉ា សឿន** ជាសមាគមនារីភូមិអូរស្វាយ ឃុំអូរស្វាយ។ ឆ្នាំ១៩៨១-១៩៨៣ ជាសមាជិកក្រុមប្រឹក្សាឃុំអូរស្វាយ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ឆ្នាំ១៩៨៤ត្រូវបានគេដូរមកធ្វើជាស្តីទីឃុំក្រឡាវិញ ធ្វើការបាន៤ខែដូរធ្វើជាអនុឃោសនាបក្សស្រុកកំពង់សៀម។ ឆ្នាំ១៩៨៥-២០១១ ជាមេឃុំក្រឡា។ លោកស្រីក៏ជាប្រធានបណ្តាញជំហានស្ត្រីដើម្បីអភិវឌ្ឍន៍នៅឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ក្រោមការដឹកនាំសកម្មភាពរបស់**គណៈកម្មាធិការខុមហ្វ្រែល**ផងដែរ។ លោកស្រីជាស្ត្រីមេម៉ាយ មានកូនប្រុស១នាក់។

ទោះបី លោកស្រីមិនធ្វើជាមេឃុំតាមសំណូមពររបស់ប្រជាពលរដ្ឋ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋគាំទ្រលោកស្រីមួយចំនួនឈប់ទៅបោះឆ្នោតក៏ដោយ ក៏លោកស្រីនៅតែរក្សាចំនួនអាសនៈរបស់គណបក្សប្រជាជនចំនួន៤អាសនៈដដែល។ តាំងពីលោកស្រីធ្វើការបំរើប្រជាពលរដ្ឋរហូតដល់សព្វថ្ងៃ លោកស្រីមិនដែលមានម៉ូតូជិះទេគឺលោកស្រីធ្វើដំណើរពីភូមិមួយទៅភូមិមួយដោយសារជិះកង់ ពេលខ្លះដើរ ពេលខ្លះជិះដោយសារគេ។

## ករណីសិក្សាទី ២ : មេឃុំថ្មីជាស្ត្រីវ័យក្មេង



កញ្ញាតឹកនីមជាវាគ្មិនក្នុងកិច្ចពិភាក្សាតុមូល នៅសណ្ឋាគារសាន់វេ ថ្ងៃទី១១កក្កដា ឆ្នាំ២០១២

**"ការភ័យខ្លាច មិនមែនជាកត្តាជោគជ័យ"** នេះជាសំដីរបស់កញ្ញា**តឹក នីម** មេឃុំថ្មីក្នុងវ័យ២៧ឆ្នាំ និងជាបេក្ខភាពគណបក្សសម រង្ស៊ី។ កញ្ញាជាកូនកសិករក្រីក្រដែលមានបងប្អូនចំនួន៦នាក់ ស្រី២នាក់ កញ្ញាជាកូនទី៣ រស់នៅភូមិតាកោង ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ក្រុមគ្រួសារកញ្ញាជាជនរងគ្រោះបាត់បង់ដីធ្លី។ កញ្ញាបានរៀបរាប់ថា *"កាលពីមុនមកខ្ញុំមិនដែលគិតថាចូលរួមក្នុងវិស័យនយោបាយ*

*ទេ ព្រោះខ្ញុំជាកូនកសិករក្រីក្រ និងមានចំណេះដឹងទាប ។បន្ទាប់ពីក្រុមគ្រួសារខ្ញុំ និងប្រជាពលរដ្ឋក្នុងភូមិក្លាយជាជនរងគ្រោះបាត់បង់ដីធ្លី ហើយស្របពេល ដែលខ្ញុំទទួលព័ត៌មានថាគណបក្សសម រង្ស៊ីមានគោលនយោបាយល្អ និងបានចូលរួមជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋពីការរំលោភបំពានដីធ្លីមក ធ្វើឱ្យខ្ញុំមានឆន្ទៈចូលរួមក្នុងវិស័យនយោបាយនៅថ្នាក់មូលដ្ឋាន ជាមួយគណបក្ស សមរង្ស៊ី* ” ។ កញ្ញាបន្ថែមទៀតថា “*ពេលខ្ញុំឈរឈ្មោះជាមេឃុំមានគណបក្សខ្លះទិញទឹកចិត្តខ្ញុំ ប្រើពាក្យ គំរាមកំហែងដែរប្រមាថមើលងាយ និងទទួលការរិះគន់ពីប្រជាពលរដ្ឋខ្លះដែលមិនមានបញ្ហាទំនាស់ដីធ្លី ពេលហ្នឹងខ្ញុំមានការភយ័ខ្លាចនិងរារែកខ្លះដែរ តែក្រោយមកខ្ញុំយល់ឃើញថា ការភ័យខ្លាចមិនមែនជាកត្តាជោគជ័យ និងរកដំណោះស្រាយបានទេ ព្រោះថាបើយើងមិនក្រោកឈរតស៊ូយើងនៅតែទទួលការគាបសង្កត់ និងការធ្វើបាបពីអ្នកមានអំណាចដដែល អញ្ចឹងយើងត្រូវតែមានឆន្ទៈប្រឈមនឹងបញ្ហាជានិច្ច* ” ។

ទាក់ទងនឹងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមេឃុំថ្មីរូបនេះបញ្ជាក់ថា “*ខ្ញុំបានរៀនច្បាប់ភូមិបាលពីអង្គការអាដហុក ហើយគណបក្សសម រង្ស៊ីបានបង្រៀន និងពន្យល់ពីគោលនយោបាយបក្ស និងនីតិវិធីយុទ្ធនាការឃោសនាបោះឆ្នោត* ”។ ប៉ុន្តែទោះបីកញ្ញាទទួលការបណ្តុះបណ្តាលតិចតួចក៏ដោយ ក៏កញ្ញាទទួលបានជោគជ័យក្នុងការបោះឆ្នោត។ កញ្ញាបានចែករំលែកបទពិសោធក្នុងការទាក់ទាញអ្នកបោះឆ្នោតថា “ *ទី១ គឺប្អូនសិក្សាពីចំនួនភូមិដែលមានប្រជាពលរដ្ឋមានបញ្ហា រួចចុះផ្ទាល់ដល់តំបន់នោះ និងខ្សឹបប្រាប់គាត់ឱ្យបោះឆ្នោតឱ្យប្អូន។ ទី២ គឺប្អូនសុំកិច្ចសហការ និងប្រឹក្សាយោបល់ពីក្រុមប្រឹក្សាចាស់ៗ ។ ទី៣ គឺប្អូននិយាយទន់ភ្លន់ រាក់ទាក់ គួរសមដល់ប្រជាពលរដ្ឋ ជាពិសេសក្រុមក្មេងស្ទាវ និងពួកជើងកាង។ ទី៤ គឺប្អូនដើរចែកខិតប័ណ្ណ និងឱសស្តីពីគោលនយោបាយបក្សសម រង្ស៊ី។ ប៉ុន្តែប្អូននៅតែជួបឧបសគ្គខ្លះ ដូចជា ពេលប្អូនដើរឃោសនារកសន្លឹកឆ្នោត ត្រូវគេជិះម៉ូតូឆាប ចំណែកប្រជាពលរដ្ឋមិនមានបញ្ហារឿងដីធ្លីគេរិះគន់ និងមិនគាំទ្រប្អូន* ”។

ឥឡូវនេះ មេឃុំស្ត្រីវ័យក្មេងរូបនេះបានចូលកាន់ដំណែងដើម្បីបំរើប្រជាពលរដ្ឋ ប៉ុន្តែកញ្ញានៅមានឧបសគ្គច្រើន ដូចជាខ្វះមធ្យោបាយធ្វើដំណើរ បទពិសោធ និងចំណេះដឹង។ កញ្ញាបានសំណូមពរដល់អង្គការខុមហ្វ្រែល និងអ្នកផ្សេងទៀតជួយផ្តល់បទពិសោធ និងថវិកាដើម្បីរៀនសូត្របន្ត។ កញ្ញាបានបង្ហាញពីឆន្ទៈផ្ទាល់ខ្លួនថា “*ខ្ញុំនឹងប្រឹងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋឱ្យបានជោគជ័យ អភិវឌ្ឍន៍ឃុំអមលាំងឱ្យរីកចំរើនបន្ថែម បើខ្ញុំមានសមត្ថភាព និងលទ្ធភាពខ្ញុំនឹងធ្វើជាអ្នកដឹកនាំ ថ្នាក់ស្រុក ថ្នាក់ខេត្ត*”។

## ករណីសិក្សាទី ៣ : មេឃុំថ្មី



លោកស្រី ជួន ចេតនាពេលជួបសម្ភាសន៍ជាមួយអ្នកសម្របសម្រួលខុមហ្វ្រែលខេត្តព្រះវិហារ

**លោកស្រី ជួន ចេតនា** ជាមេឃុំថ្មី វ័យ៤៥ឆ្នាំ មានកូន៥នាក់ ស្រី១នាក់។ មុនជាប់ជាមេឃុំ លោកស្រីមានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារ។

លោកស្រីបានរៀបរាប់ថា *កត្តាចំបងដែលធ្វើឱ្យលោកស្រីបានឈរឈ្មោះនៅលេខរៀងទី១ និងបានជាប់ជាមេឃុំ គឺដោយសារលោកស្រីមានភាព ក្លាហានប្រឈមមុខគ្រប់ឧបសគ្គ ជួយប្រជាពលរដ្ឋទាន់ពេលវេលា មិនថាយប់ ឬថ្ងៃ។ មានបទពិសោធការងារក្នុងជួរក្រុមប្រឹក្សាចំនួនពីរអាណត្តិ មានប្រជាប្រិយភាពក្នុងឃុំ មានការគាំទ្រពីគណបក្សប្រជាជនកម្ពុជា និងក្រុមប្រឹក្សាទាំងអស់ក្នុងឃុំ* ។ លោកស្រីបន្តទៀតថា *" បញ្ហាសំខាន់ៗដែលខ្ញុំលើកយកមកធ្វើការឃោសនាក្រៅពីគោលនយោបាយ១១ចំណុចរបស់គណបក្សប្រជាជនកម្ពុជាគឺ ការសន្យាមិនយកពន្ធលើដីបង្កបង្កើនផលរបស់ប្រជាពលរដ្ឋក្នុងភូមិ ឃុំ ។ ការជួយផ្តល់សេវាដល់ស្ត្រីក្រីក្រទៅសម្រាលកូននៅមណ្ឌលសុខភាព និងសន្យាប្រឹងប្រែងរកដៃគូរអភិវឌ្ឍន៍ដើម្បីអភិវឌ្ឍភូមិ ឃុំ "* ។ ចំណែកវិធីសាស្ត្រដែលខ្ញុំប្រើដើម្បីទាក់ទាញការគាំទ្រពីប្រជាពលរដ្ឋក្នុងឃុំគឺ *ខ្ញុំបង្កើនទំនួលខុសត្រូវការងារ តស៊ូ និងឧស្សាហ៍ចុះជាប់ជាមួយប្រជាពលរដ្ឋ ដើម្បីអប់រំណែនាំពួកគាត់ ។ សំខាន់ខ្ញុំជាបណ្តាញស្ត្រីរបស់ខុមហ្វ្រែល ខ្ញុំបានចូលរួមអប់រំដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសស្ត្រីនូវប្រធានបទមួយចំនួនដូចជាសុខភាពមាតា និងទារក អំពើហឹង្សាក្នុងគ្រួសារ យេនឌ័រ សារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ ការទប់ស្កាត់គ្រឿងញៀន និងអប់រំស្ត្រីវ័យក្មេងពីសុខភាពបន្តពូជ មិត្តអប់រំមិត្ត ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋស្គាល់ និងស្រលាញ់ខ្ញុំច្រើន "*។

ទន្ទឹមនឹងនោះលោកស្រីជួបបញ្ហាប្រឈមខ្លះដូចជា ពុំសូវមានពេលវេលាថែទាំកូន និងក្រុមគ្រួសារ គ្រួសារព្រួយបារម្ភពីសុខភាពដោយសារហូបចុកមិនទៀងពេលវេលា និងទទួលការរិះគន់ពីប្រជាពលរដ្ឋមួយចំនួនក្នុងមូលដ្ឋាន។ លោកស្រី បានបញ្ជាក់ថា *" បុរសក្នុងមូលដ្ឋានខ្លះគេនិយាយថាស្ត្រីធ្វើជាមេឃុំមិនសមដូចបុរស ព្រោះស្ត្រីពុំសូវមានចំណេះដឹង ធ្វើដំណើរផ្លូវឆ្ងាយពិបាក ដូចជាធ្វើដំណើរទៅផ្លូវឆ្ងាយៗ ម៉ូតូខូចតិចតួចមិនចេះធ្វើសោះផងហ្នឹង។ ចំណែក ស្ត្រីខ្លះរិះគន់ថា ប្រុសគគោកម៉េចមិនយកធ្វើជាមេឃុំ បែរជាយកស្រីទៅវិញ ប្រុសគេធ្វើមេឃុំសមជាង ស្រីចេះដឹងតិច ចិត្តមិនលុះ ប្រុសៗគេចេះដឹងច្រើន ក្លាហានហើយដើរទៅណាឆ្ងាយរហ័សរហួនជាងស្រី "*។

**លោកស្រី ជួន ចេតនា** រៀនបានថ្នាក់ទី៤ថ្មី និងធ្លាប់ទទួលការបណ្តុះបណ្តាលពី**អង្គការខុមហ្វ្រែល** អង្គការចំរើនស្ត្រី អង្គការវ៉ាឆា មន្ទីរកិច្ចការនារី មន្ទីរកសិកម្ម និងមន្ទីរសុខាភិបាល ។ ឆ្នាំ១៩៨៤ ដល់១៩៩៣ លោកស្រីជាបុគ្គលិកសាលាខេត្តព្រះវិហារ ។ ឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០១ ជាប្រជាពលរដ្ឋ និងជាអនុប្រធានភូមិ ។ ឆ្នាំ២០០២ មេឃុំរប៉ាសបានទៅទំនាក់ទំនងឱ្យលោកស្រីឈរឈ្មោះជាសមាជិកក្រុមប្រឹក្សា និងជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាតាំងពីឆ្នាំ២០០២ ដល់ឆ្នាំ២០១១ ។

មូលហេតុលោកស្រីចូលរួមក្នុងវិស័យនយោបាយគឺ ចង់មានឱកាសក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ព្រោះស្ត្រីអាចជួយដោះស្រាយបញ្ហាស្ត្រីបានច្រើន ចង់ឱ្យសម្លេងស្ត្រីមានច្រើនតាំងពីថ្នាក់មូលដ្ឋានរហូត ដល់ថ្នាក់ជាតិ ។ លោកស្រីបានផ្តាំផ្ញើដល់ប្រជាពលរដ្ឋជាស្ត្រីទាំងអស់ថា *"សូមឱ្យស្ត្រីទាំងអស់ត្រូវមានសេចក្តីក្លាហានចូលរួមការងារ សង្គម និងវិស័យនយោបាយឱ្យបានច្រើនតាំងពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ ដើម្បីលើកស្ទួយតម្លៃស្ត្រី និងសមភាពយេនឌ័រ"* ។

## ២. កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្ស អំពី បញ្ហាស្ត្រី

ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២ ចាប់ពីថ្ងៃទី១៨ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ (១៥ថ្ងៃ) គណបក្សនយោបាយទាំង១០បានធ្វើសកម្មភាពឃោសនាដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ។ ជាមួយគ្នានេះដែរ គណបក្សមួយចំនួនក៏បានបង្ហាញដល់អ្នកបោះឆ្នោតនូវកម្មវិធីនយោបាយទាក់ទិនបញ្ហាស្ត្រី និងកុមារ ដើម្បីដោះស្រាយក្នុងអាណត្តិទី៣នេះផងដែរ ។

កម្មវិធីនយោបាយ និងការសន្យាសំខាន់ខាងក្រោមនេះ បានដកស្រង់ចេញពីឯកសាររបស់អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ (DHRAC) និងគណៈកម្មាធិការតស៊ូមតិនៃសមាគម-អង្គការមិនមែនរដ្ឋាភិបាល (AT) ស្តីពី "ព័ត៌មានស្តីពីការបោះឆ្នោត" តាមលិខិតយល់ព្រមលេខ០៥.០៤៦/១២ គ.ជ.ប.អគ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១២ ដោយគណៈកម្មាធិការជាតិរៀបចំបោះឆ្នោត និងដកស្រង់ចេញពីរបាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែល ស្តីពី "ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ឆ្នាំ២០១២" ក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ ព្រមទាំងដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ៥ខេត្តគឺ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ ។

## តារាងទី ៣ : កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ

| ល.រ | កម្មវិធីនយោបាយរបស់គណបក្ស | ឈ្មោះគណបក្សនយោបាយ |
|---|---|---|
| ១ | អភិវឌ្ឍន៍ឃុំសង្កាត់ឱ្យរីកចម្រើនប្រកបដោយចីរភាពលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សុខាភិបាល និងយេនឌ័រ ។ | គណបក្សប្រជាជនកម្ពុជា |
| ២ | យកចិត្តទុកដាក់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងការកាត់បន្ថយការធ្វើចំណាកស្រុក ។ ជំរុញការអភិវឌ្ឍតំបន់ជនជាតិដើមភាគតិចឱ្យមានការរីកចម្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្របជាមួយនឹងការរីកចម្រើនជាទូទៅនៃសង្គមជាតិ ។ | គណបក្សប្រជាជនកម្ពុជា |
| ៣ | សេវាកម្មដ៏ច្រើនបម្រើឱ្យកម្មវិធីវិនិយោគ និងអភិវឌ្ឍន៍ភូមិ ឃុំ ក៏កាត់បន្ថយពលករ/ពលការិនីចំណាកស្រុកដែលឆ្លងដែនត្រូវគេជិះជាន់ និងជាផ្សារការងារតម្លៃខ្ពស់នៃអតិថិជន និងពិការជនផងដែរ | គណបក្សហ៊្វុនស៊ិនប៉ិច |
| ៤ | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងផ្តល់ព័ត៌មានទីផ្សារការងារជូនដល់ប្រជាពលរដ្ឋជាពិសេសយុវជន យុវនារីនៅក្នុងមូលដ្ឋាន ។ | គណបក្សសិទ្ធិមនុស្ស |
| ៥ | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មានគោលការណ៍សំខាន់ៗដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ និងបញ្ហាផ្សេងៗទៀត ។ | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ |
| ៦ | ធានាផ្តល់នូវសេវាសាធារណៈជូនមន្ត្រីរាជការ កម្មករ-កម្មការិនីរោងចក្រ និងស្ត្រីបុរសកម្មករសំណង់ ស្ត្រី-បុរសចំណាកស្រុក ស្ត្រី-បុរសអាជីវករ ព្រមទាំងនិស្សិត និងយុវជន-យុវនារី ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។ | គណបក្សនរោត្តម រណឫទ្ធិ |
| ៧ | ចំពោះនិស្សិត និងយុវជន-យុវនារី គណបក្សនរោត្តម រណឫទ្ធិ យកចិត្តទុកដាក់ ទី១. បង្កើតការងារនៅក្នុងស្រុក ។ ទី២. ផ្តល់ឱកាសឱ្យមានការងារស្របតាមសមត្ថភាព ។ ទី៣. ផ្តល់លទ្ធភាព និងតួនាទីឱ្យនិស្សិត យុវជន-យុវនារីបានចូលរួមអភិវឌ្ឍន៍នៅក្នុងប្រទេស ។ ទី៤. ផ្តល់ឱកាសឱ្យទទួលបាននូវវគ្គបណ្តុះបណ្តាលសមត្ថភាព និងជំនាញស្របតាមតម្រូវការទីផ្សារ ។ | គណបក្សនរោត្តម រណឫទ្ធិ |

គួរកត់សម្គាល់ថា ទោះបីកម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សខ្លះ បានបង្ហាញការយកចិត្តទុកដាក់តិចតួចក្នុងការដោះស្រាយបញ្ហាស្ត្រី គណបក្សខ្លះមិនយកចិត្តទុកដាក់ទាល់តែសោះអំពីបញ្ហាស្ត្រី តួយ៉ាង គណបក្សប្រឆាំងធំជាងគេ គណបក្សសម រង្ស៊ី និងគណបក្សពុំសូវមានប្រជាប្រិយភាព ដូចជា គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសញ្ជាតិកម្ពុជា និងគណបក្សចលនាប្រជាធិបតេយ្យ ប៉ុន្តែ បែរជាបេក្ខជនស្ត្រីរបស់គណបក្សនីមួយៗ បានបង្ហាញពីការសន្យារបស់ខ្លួនយ៉ាងពិសេសទាក់ទិននឹងបញ្ហាស្ត្រី និងកុមារដើម្បីដោះស្រាយនៅអាណត្តិទី៣នេះ ។

**តារាងទី ៤ : កម្មវិធីនយោបាយរបស់គណបក្សតាមឃុំ សង្កាត់នីមួយៗ ដែលបានសន្យាដោយបេក្ខជនស្ត្រី ដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ**

ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ឆ្នាំ២០១២នេះ បេក្ខជនស្ត្រីឈរឈ្មោះ បានធ្វើការឃោសនាតាមកម្មវិធីនយោបាយថ្នាក់ជាតិ បង្ហាញពីសមិទ្ធផលដែលបានកសាងទាំងអស់ក្នុងឃុំ សង្កាត់ក្នុងរយៈពេល៥ឆ្នាំកន្លងមក និងបានធ្វើការ**សន្យាបន្ថែម**ទៅតាមតម្រូវការក្នុងឃុំ សង្កាត់ដោយឡែកៗពីគ្នាទាក់ទិននឹងបញ្ហាស្ត្រី និងកុមារ ។ ការសន្យាសំខាន់ៗតាមឃុំ សង្កាត់នេះ បានដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ៥ខេត្ត គឺ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ ។

| ល.រ | កម្មវិធីនយោបាយរបស់គណបក្សតាមឃុំ សង្កាត់ | បេក្ខជនស្ត្រី | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | នឹងធ្វើផ្លូវមួយខ្សែទៀត ជូនប្រជាពលរដ្ឋ និងយកចិត្តទុកដាក់បន្ថែម អំពីបញ្ហាសុខភាព មាតា និងទារក ។ | លោកស្រី **អ៊ា ចាន់ថុល** ជាប់ឆ្នោតជា **មេឃុំ** ក្បៀនជ្រៃ ស្រុក កំពង់សៀម ខេត្ត កំពង់ចាម | **គណបក្សប្រជាជនកម្ពុជា** |
| ២ | ជួយរកមធ្យោបាយដឹកជញ្ជូនស្ត្រី ក្រីក្រ ឈឺពោះឆ្លងទន្លេពេលយប់ ទៅមណ្ឌលសុខភាព ។ | លោកស្រី **ស្រី សុខា** ជាប់ឆ្នោតជា **ជំទប់ទី១** នៅឃុំ ម្សាក្រង ស្រុក ស្ទួង ខេត្ត កំពង់ធំ | **គណបក្សប្រជាជនកម្ពុជា** |
| ៣ | សន្យាជម្រុញឱ្យក្មេង ដែលបោះបង់ចោលសាលា ចូលរៀនឡើងវិញ និងជម្រុញឱ្យស្ត្រីនៅក្នុងឃុំ ទៅពិនិត្យសុខភាព នៅមណ្ឌលសុខភាព ឱ្យបាន គ្រប់ៗគ្នា ។ | លោកស្រី **ម៉ុល សុភាព** ជាប់ឆ្នោតជា **ជំទប់ទី១** នៅឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្តកំពង់ ឆ្នាំង | **គណបក្សសម រង្ស៊ី** |

| | | | |
|---|---|---|---|
| ៤ | ផ្តល់ថវិកា ធ្វើដំណើរដល់ស្ត្រី ដែលទៅ ឆ្លងទន្លេ នៅ មណ្ឌលសុខភាព | លោកស្រី **សេង ចាន់ថូ** ជាប់ឆ្នោតជា **ជំទប់ទី១** នៅឃុំទៀល ស្រុក បារាយណ៍ ខេត្ត កំពង់ធំ | **គណបក្ស សម រង្ស៊ី** |
| ៥ | មិនយកថវិកា ចំពោះស្ត្រី ដែលទៅពិនិត្យសុខភាព នៅមណ្ឌលសុខភាព។ ចិញ្ចឹមមនុស្សចាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើង ក្នុង១ខែ ១០ដុល្លារ និង ចិញ្ចឹមជនពិការ។ | លោកស្រី **អាំ ណន់** ជាបេក្ខនារីឈរឈ្មោះនៅលេខរៀងទី៥ **មិនបាន ជាប់ឆ្នោត** នៅឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | **គណបក្ស សិទ្ធិមនុស្ស** |
| ៦ | ជួយផ្នែកគាំពារសុខភាពមាតា និងទារក ពេលស្ត្រីមានផ្ទៃពោះ ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយទៅមណ្ឌលសុខភាពមិនយកថវិកា និងជួយជាសោហ៊ុយធ្វើដំណើរ | លោកស្រី **ធូ ប៉ែត** ជាបេក្ខនារីឈរឈ្មោះនៅលេខរៀងទី៣ **មិនបាន ជាប់ឆ្នោត** នៅឃុំ តាភេម ស្រុក ត្រាំកក់ ខេត្ត តាកែវ | **គណបក្ស សិទ្ធិមនុស្ស** |
| ៧ | កាត់បន្ថយ និងលុបបំបាត់ អំពើហិង្សា ក្នុងគ្រួសារ នៅ ក្នុងឃុំ។ | -លោកស្រី **ខៀវ ផន** ជាបេក្ខនារីឈរឈ្មោះនៅលេខរៀងទី២ **មិនបាន ជាប់ឆ្នោត** នៅឃុំ អង្គតាសោម ស្រុក ត្រាំកក់ ខេត្តតាកែវ។<br>-លោកស្រី **ប៊ូ ម៉ុត** ជាបេក្ខនារីឈរឈ្មោះនៅលេខរៀងទី១ **មិនបាន ជាប់ឆ្នោត** នៅឃុំ ត្រាំកក់ ស្រុក ត្រាំកក់ ខេត្តតាកែវ។ | **គណបក្ស ហ៊្វុនស៊ិនប៉ិច**<br>**គណបក្ស នរោត្តម រណឫទ្ធិ** |
| ៨ | ជួយផ្តល់ថ្លៃសេវាដល់ស្ត្រី ក្រីក្រ ទៅសម្រាលកូននៅ មណ្ឌលសុខភាព។ | លោកស្រី **ជួន ចេតនា** ជាប់ឆ្នោតជា **មេឃុំ** រហ័ស ស្រុក រវៀង ខេត្ត ព្រះវិហារ | **គណបក្ស ប្រជាជនកម្ពុជា** |

របាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែល[២] ស្តីពីការចូលរួមក្នុងនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣នេះ នៅក្នុងខេត្តតាកែវ ស្រុកកោះអណ្តែត ចំនួន៥ឃុំ គឺ ឃុំរមេញ ឃុំក្រពុំឈូក ឃុំព្រៃខ្លា ឃុំធ្លាប្រជុំ និងឃុំពេជសារ បានរកឃើញថា ក្នុងអំឡុងពេលយុទ្ធនាការឃោសនាគណបក្សនយោបាយ៥ដែលចូលរួមប្រកួតប្រជែងគឺ គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ៊្វុនស៊ិចប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ សុទ្ធតែបានលើកយកបញ្ហាស្ត្រី និងកុមារដើម្បីដោះស្រាយក្នុងអាណត្តិទី៣នេះ។ គោលនយោបាយទាក់ទិននឹងបញ្ហាស្ត្រី និងកុមារ មានដូចជា *លើកកម្ពស់តួនាទី និងស្ថានភាពស្ត្រីក្នុងសង្គម ការពង្រឹងសិទ្ធិស្ត្រីក្នុងការទទួលការថែទាំសុខភាព ការសិក្សាការបណ្តុះបណ្តាលវិជ្ជាជីវៈ ឱកាសការងារ ។ បង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិតឱ្យបានជាអតិបរមាក្នុងវិស័យនយោបាយ ស្ថាប័នជាតិ និងអង្គការសង្គមផ្សេងៗ ។ បង្កើតគោលនយោបាយយេនឌ័រ និងប្រព័ន្ធកូតា ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការផ្តល់អំណាចដល់ស្ត្រីក្នុងការធ្វើការសម្រេចចិត្ត ។ លើកកម្ពស់តម្លៃស្ត្រី រាំងស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការជួញដូរស្ត្រី កុមារតាមគ្រប់រូបភាព និងគ្រឿងញៀនគ្រប់ប្រភេទ។ អង្កេត តាមដានរាល់សកម្មភាពរបស់ក្រុមហ៊ុនដែលនាំពលករ-ពលការិនីឱ្យទៅធ្វើការនៅក្រៅប្រទេសដែលស្ថិតនៅក្នុងឃុំ សង្កាត់។ លើកកម្ពស់លក្ខខណ្ឌការងាររបស់កម្មករ និយោជិតគ្រប់ផ្នែកដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់។ ពង្រីកកម្មវិធី គាំពារមាតា និងទារក។ លើកស្ទួយសិទ្ធិកុមារ កុមារកំព្រា កុមារពិការ កុមារមកពីគ្រួសារក្រីក្រ។*

## ៣. អ្នកបោះឆ្នោតស្ត្រី

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ឆ្នាំ២០១២នេះ ចំនួនប្រជាពលរដ្ឋដែលបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការសរុប **៩ ២០៣ ៤៩៣នាក់** ក្នុងនោះស្ត្រីមានចំនួន **៤ ៨៦១ ៨៩៣នាក់** ស្មើនឹង **៥២,៨២%**[៣] ។ យោងតាមលទ្ធផលសង្កេតស្រាវជ្រាវបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឆ្នាំ២០១១ បានបង្ហាញថា ភាគរយនៃស្ត្រីចុះឈ្មោះបោះឆ្នោតមាន ៩៤,១០% ប្រហាក់ប្រហែលនឹងភាគរយបុរស ៩៤,៤០%។

មានអ្នកបោះឆ្នោត ចំនួនតែ **៥ ៩៨៥ ៤៩៨នាក់ (៦៥,០៣%)** ប៉ុណ្ណោះ ក្នុងនោះតាមការប៉ាន់ស្មានអ្នកបោះឆ្នោតស្ត្រីច្រើនជាងបុរស**បានទៅបោះឆ្នោត**នៅថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២។

---

[2] ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ជាស្ត្រីរយៈពេលវែង និងរយៈពេលខ្លីចំនួន ៦០នាក់ ក្នុងខេត្តតាកែវ ស្រុកកោះអណ្តែត ចំនួន៥ឃុំ គឺ ឃុំរមេញ ឃុំក្រពុំឈូក ឃុំព្រៃខ្លា ឃុំធ្លាប្រជុំ និងឃុំពេជសារ។

[3] របាយការណ៍របស់គ.ជ.ប ស្តីពី ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ប្រចាំឆ្នាំ២០១១ ចេញផ្សាយ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១

អ្នកមានសិទ្ធិបោះឆ្នោតចំនួន **៣ ២១៨ ០៣៩នាក់** (៣៤,៩៧%) **មិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត** ។ ការខកខានមិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោតនេះ ក៏អាចមានស្ត្រីមួយចំនួនធំផងដែរ។ ពួកគេពិតជាជួបការលំបាកក្នុងការទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយសារមានភាពមិនប្រក្រតីមួយចំនួនដែលប៉ះពាល់ដល់សិទ្ធិអ្នកបោះឆ្នោត ជាពិសេសអ្នកបោះឆ្នោតជាស្ត្រី ដូចជា ( ***១) បាត់ឈ្មោះ និងរកឈ្មោះពួកគេមិនឃើញនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត (២) ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត***។

របាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែលស្តីពីការចូលរួមរបស់ស្ត្រីក្នុងខេត្តតាកែវបានរកឃើញទៀតថា ក្នុងចំណោម ៦០ការិយាល័យបោះឆ្នោត មានការិយាល័យបោះឆ្នោតចំនួន១០ កើតមានភាពមិនប្រក្រតីមកលើស្ត្រី ដែលមានចំនួនសរុប ២៩ករណី ក្នុងនោះ ឃុំក្រពុំឈូក មាន១៩ករណី ឃុំពេជសារមាន ៥ករណី ឃុំរមេញមាន៤ករណី និងឃុំព្រៃខ្លាមាន១ករណី។ ក្នុងចំណោម២៩ករណី មាន២៧ករណីដែលរារាំងដល់ការបោះឆ្នោតរបស់ស្ត្រី គឺ **បាត់ឈ្មោះ រកឈ្មោះមិនឃើញ និងខុសទិន្នន័យ**ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត។

ខុមហ្វ្រែលបានសិក្សាស្រាវជ្រាវចំពោះអ្នកដែលមិនបានទៅបោះឆ្នោត ពីមូលហេតុដែលមិនបានទៅបោះឆ្នោត។ ក្នុងនោះមានស្ត្រីផ្តល់បទសម្ភាសន៍ប្រមាណ ៥១,១០% នៃអ្នកផ្តល់បទសម្ភាសន៍សរុប។ ក្នុងចំណោមស្ត្រីដែលមិនបានទៅបោះឆ្នោត មាន ៥១,២០% បានទៅបោះឆ្នោត ប៉ុន្តែបានជួបឧបសគ្គដែលក្នុងនោះ ភាគច្រើនរកឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតមិនឃើញ និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត។

## III- សេចក្តីសន្និដ្ឋាន និងសង្ខេប

ជាសរុប **"មានភាពប្រសើរឡើងតិចតួច ប៉ុន្តែមិនទាន់ដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជាចំពោះចំនួនកំណើនស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ និងជាប់ឆ្នោត ហើយក៏មានការថយចុះវិសមភាព និងការរើសអើងយេនឌ័រ"**។ មានការប្រឈម និងបញ្ហាជាច្រើនទៀតដែលត្រូវកែលម្អ រួមទាំងគុណភាពនៃការចូលរួមរបស់ស្ត្រី។ នៅមានឧបសគ្គដែលរារាំងដល់ការអនុវត្តសមភាពយេនឌ័រជាតំណាងជាប់ឆ្នោត។ ក្រៅពីវិធានការច្បាប់ និងការលើកទឹកចិត្តដល់គណបក្សនយោបាយ វិធានការគាំទ្រដល់បេក្ខនារី និងស្ត្រីជាប់ឆ្នោតក៏សំខាន់ណាស់ដែរ និងការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយអំពីសារៈសំខាន់របស់ស្ត្រីក្នុងការងារនយោបាយ ការបោះឆ្នោត និងការសម្រេចចិត្ត។

មានអ្នកបោះឆ្នោតស្ត្រីច្រើនជាងបុរសបានចេញទៅបោះឆ្នោតនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២។

ទិន្នន័យ និងលទ្ធផលស្រាវជ្រាវ ការសង្កេតទៅលើការចូលរួមរបស់ស្ត្រីបានរកឃើញថា អ្នកបោះឆ្នោតស្ត្រីដែលខកខានមិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត ដោយសារពួកគេជួបនូវភាពមិនប្រក្រតីមួយចំនួនដែលប៉ះពាល់ដល់សិទ្ធិបោះឆ្នោត ដូចជា បាត់ឈ្មោះ និងរកឈ្មោះមិនឃើញ ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ព្រមទាំងជាប់រវល់នឹងកិច្ចការផ្ទះ។

ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ដែលមានរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃទី១៨ ខែឧសភា ដល់ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ គណបក្សនយោបាយទាំង១០បានធ្វើសកម្មភាពឃោសនាដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់។ នៅក្នុងកម្មវិធីនយោបាយថ្នាក់ជាតិ គណបក្សនយោបាយមានការយកចិត្តទុកដាក់តិចតួចក្នុងការដោះស្រាយបញ្ហាស្ត្រី ហើយគណបក្សខ្លះមិនយកចិត្តទុកដាក់ទាល់តែសោះអំពីបញ្ហាស្ត្រី។ ទោះជាយ៉ាងនេះក្តី បេក្ខជនស្ត្រីរបស់គណបក្សនីមួយៗជាពិសេសគណបក្សដែលមានអាសនៈនៅសភា បានបង្ហាញពីការសន្យារបស់ខ្លួនទៅតាមតម្រូវការក្នុងឃុំ សង្កាត់ដោយឡែកៗពីគ្នាទាក់ទិននឹងបញ្ហាស្ត្រី និងកុមារ។

## IV- អនុសាសន៍

ដើម្បីលើកកំពស់សមភាពយេនឌ័រ និងផ្តល់អំណាចនយោបាយដល់ស្ត្រី វិធានការមួយចំនួនគួរតែដោះស្រាយដូចជា ៖

### ១. ការកំណត់គោលនយោបាយរបស់គណបក្សស្តីពីប្រពន្ធ័កូតា

**"ប្រពន្ធ័កូតា"** ជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយដែលអាចលើកទឹកចិត្តឱ្យគ្រប់គណបក្សនយោបាយដាក់បេក្ខជនស្ត្រីក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ការលើកទឹកចិត្តដើម្បីបង្កើតប្រពន្ធ័កូតាក្នុងគណបក្សនយោបាយក៏អាចត្រូវបានបង្កើតក្នុងក្របខណ្ឌច្បាប់ដែរ គឺនិយាយដល់ការធ្វើវិសោធនកម្មច្បាប់សម្រាប់ការបោះឆ្នោត។ វិសោធនកម្មច្បាប់នេះកែលម្អបន្ថែមលក្ខណៈនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យមានប្រពន្ធ័កូតា៣០% និងដាក់ឆ្លាស់សម្រាប់បេក្ខជនបុរស ឬស្ត្រី និងបង្កើតគោលនយោបាយសម្រាប់រដ្ឋផ្តល់មូលនិធិដល់គណបក្សនយោបាយណាដែលគោរព និងអនុវត្តតាមច្បាប់នេះ។ មូលនិធិរបស់រដ្ឋ ត្រូវបានអនុមត័ចេញពីថវិកាជាតិដើម្បីឱ្យទៅគណបក្សនយោបាយសម្រាប់ធ្វើការបណ្តុះបណ្តាលដល់បេក្ខជន ពិសេសបេក្ខនារីក្នុងកិច្ចការងារនយោបាយ និងការបោះឆ្នោត។

**២. លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី**

ត្រូវផ្តល់ឱកាសចំពោះស្ត្រី និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងទាំងឡាយ ដើម្បីលើកតម្កើង និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ ធ្វើយ៉ាងណាឱ្យមានសមភាពនៃតំណាងអ្នកជាប់ឆ្នោតរវាងស្ត្រី និងបុរស រួមទាំងទទួលបាននូវអំណាចនយោបាយស្មើគ្នាតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។

**៣. ការពង្រឹងសមត្ថភាពស្ត្រី**

ចាំបាច់ត្រូវផ្តល់វគ្គហ្វឹកហ្វឺនខ្លីៗពង្រឹងសមត្ថភាពដល់បេក្ខជនស្ត្រី និងស្ត្រីជាប់ឆ្នោត ដើម្បីបង្កើនភាពជឿជាក់និងប្រសិទ្ធភាពការងារក្រោយពេលជាប់ឆ្នោត។ ជាងនេះទៅទៀត ត្រូវមានការរៀបចំ និងបណ្តុះបណ្តាលដល់អ្នកដឹកនាំជាស្ត្រីដែលមានសក្តានុពល និងសកម្មជនស្ត្រីនយោបាយជំនាន់ក្រោយទៀត។

**៤. បរិយាកាសនយោបាយល្អ**

បង្កើតបរិយាកាសល្អសម្រាប់ស្ត្រី និងធានានូវសុវត្ថិភាពសម្រាប់បេក្ខនារី។ រាជរដ្ឋាភិបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងគ.ជ.បបន្តអនុវត្តន៍ឱ្យបានតឹងរ៉ឹងនូវវិធានការពិសេស និងអន្តរាគមន៍ក្នុងការបញ្ឈប់រាល់សកម្មភាពគំរាមកំហែង បំភិតបំភ័យ និងអំពើហិង្សាលើអ្នកបោះឆ្នោតស្ត្រី បេក្ខនារី និងសកម្មជនស្ត្រីនយោបាយ។

**៥. ចែករំលែកព័ត៌មានតាមប្រពន្ធ័ផ្សព្វផ្សាយ**

ព័ត៌មាន ត្រូវតែមានលក្ខណៈងាយស្រួលក្នុងការទទួលបានសំរាប់ប្រជាពលរដ្ឋមូលដ្ឋានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។ ប្រពន្ធ័ផ្សព្វផ្សាយត្រូវចែករំលែកព័ត៌មាន និងផ្សព្វផ្សាយជាសាធារណៈពិសេសសហគមន៍មូលដ្ឋាន*អំពីសារៈសំខាន់ និងតួនាទីរបស់ស្ត្រីនៅវិស័យនយោបាយ ការងារបោះឆ្នោត ការបំពេញភារកិច្ច និងសមិទ្ធិផលដែលពួកគេសម្រេចបានមុន និងក្នុងពេលដែលស្ត្រីកំពុងបំពេញការងារ ការសម្រេចចិត្ត ការគ្រប់គ្រង និងការចាត់ចែងធនធាន*ជាដើម។ សេចក្តីត្រូវការផ្សេងទៀត គឺបង្កើនប្រសិទ្ធភាពបញ្ជូនព័ត៌មាន និងធ្វើការអប់រំប្រជាពលរដ្ឋមូលដ្ឋាន អំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះឆ្នោតដោយប្រជាពលរដ្ឋ ការទទួលខុសត្រូវ និងអាណត្តិ (អំណាចចាត់ចែងការងារដែលច្បាប់ប្រគល់ឱ្យ) របស់ពួកគេ។ ធ្វើដូចនេះ ប្រជាពលរដ្ឋនឹងមានការយល់ដឹងកាន់តែច្បាស់អំពីឥទ្ធិពលនៃបេក្ខភាពស្ត្រី (បេក្ខនារី និងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់)។

---- ចប់----